**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**
លេខ ២៤៩ ព.ណ.អ.ភ.អម.ប្រក

# ប្រកាស
## ស្តីពី
## បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតបញ្ជាក់អនុលោមភាព លើអត្ថបទឬស្ពតផ្សាយពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ២៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងកំណត់បែបបទនិងនីតិវិធីនៃការស្នើសុំលិខិតបញ្ជាក់អនុលោមភាពលើអត្ថបទឬស្ពតផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា។



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ២ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិងសេវា តាមគ្រប់ទម្រង់និងតាមគ្រប់មធ្យោបាយ រួមទាំងតាមមធ្យោបាយឌីជីថលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

បុគ្គលផ្សាយពាណិជ្ជកម្ម បុគ្គលទទួលសិទ្ធិឱ្យចាត់ចែងផ្សាយពាណិជ្ជកម្ម ផលិតករ សេវាករ ឬអ្នកនាំចូល អាចដាក់ពាក្យស្នើសុំលិខិតបញ្ជាក់អនុលោមភាពលើអត្ថបទឬស្លាកផ្សាយពាណិជ្ជកម្មនៅនាយកដ្ឋានកិច្ចការពារអ្នកប្រើប្រាស់នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ «ក.ប.ប.» នៃក្រសួងពាណិជ្ជកម្ម មុននឹងដំណើរការផ្សាយពាណិជ្ជកម្ម។

**ប្រការ៤ ._**

បុគ្គលស្នើសុំលិខិតបញ្ជាក់អនុលោមភាពលើអត្ថបទឬស្លាកផ្សាយពាណិជ្ជកម្មត្រូវភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម៖

- ពាក្យស្នើសុំ — ១ច្បាប់(មានគំរូ)
- ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ការចុះបញ្ជីក្រុមហ៊ុន ការចុះបញ្ជីម៉ាក) — ១ច្បាប់
- ច្បាប់ចម្លងលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមវិស័យ — ១ច្បាប់
- ច្បាប់ចម្លងលិខិតបញ្ជាក់ភាពត្រឹមត្រូវនៃផលិតផលទំនិញនិង/ឬសេវា ( ចបផ GHP GMP HACCP ISO FSC ) — ១ច្បាប់
- ច្បាប់ចម្លងប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ/ពន្ធអាករលើតម្លៃបន្ថែម( VAT )ចំពោះអាជីវកម្មដែលជាប់ពន្ធតាមរបបស្វ័យប្រកាស — ១ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែនឬលិខិតដែលមានតម្លៃស្មើ — ១ច្បាប់
- ប្រសិនបុគ្គលស្នើសុំជាបុគ្គលទទួលបានសិទ្ធិឱ្យចាត់ចែងផ្សាយពាណិជ្ជកម្មត្រូវមានលិខិតផ្ទេរសិទ្ធិពីក្រុមហ៊ុនជាកម្មសិទ្ធិករឬសេវាករ — ១ច្បាប់
- ច្បាប់ចម្លងជាអាទិ៍ ទិដ្ឋាការ បញ្ជិកា ប្រតិវេទន៍ ដែលតម្រូវដោយក្រសួង ស្ថាប័នឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ — ១ច្បាប់
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវា — ១ច្បាប់

**ប្រការ៥ ._**

សេចក្តីព្រាងអត្ថបទឬស្លាកផ្សាយពាណិជ្ជកម្ម ត្រូវសរសេរជាភាសានិងអក្សរខ្មែរ។

ករណីអត្ថបទឬស្លាកផ្សាយពាណិជ្ជកម្មត្រូវផ្សាយជាភាសានិងអក្សរបរទេស បុគ្គលស្នើសុំត្រូវបកប្រែជាភាសានិងអក្សរខ្មែរភ្ជាប់មកជាមួយ។

អត្ថបទឬស្លាកផ្សាយពាណិជ្ជកម្ម១(មួយ) អាចធ្វើការផ្សាយពាណិជ្ជកម្មច្រើនទម្រង់និងច្រើនមធ្យោបាយរួមទាំងមធ្យោបាយឌីជីថល។

ការផ្សាយពាណិជ្ជកម្មជាសំលេងឬជារូបភាពវីដេអូ បុគ្គលស្នើសុំអាចភ្ជាប់មកជាមួយនូវការថតសំលេងជា CD ជារូបភាព VCD ឬUSB...(ប្រសិនបើមាន)។

**ប្រការ៦ ._**

បុគ្គលស្នើសុំលិខិតបញ្ជាក់អនុលោមភាពលើអត្ថបទឬស្លាតផ្សាយពាណិជ្ជកម្មត្រូវបង់ប្រាក់កម្រៃសេវាតាមចំនួនអត្ថបទឬស្លាតផ្សាយពាណិជ្ជកម្មនិងសុពលភាពនៃការផ្សាយពាណិជ្ជកម្ម។

ការសុំបន្តសុពលភាពលើអនុលោមភាពនៃការផ្សាយពាណិជ្ជកម្ម បុគ្គលស្នើសុំត្រូវបង់កម្រៃសេវាតាមជម្រើសនៃការស្នើសុំ។

កម្រៃសេវានេះមិនត្រូវបានប្រគល់ជូនបុគ្គលស្នើសុំ ទោះបីមានការបដិសេធលើការស្នើសុំក៏ដោយ។

**ប្រការ៧ ._**

លិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិង/ឬសេវាមានសុពលភាពមិនលើសពី១(មួយ)ឆ្នាំ។

បុគ្គលស្នើសុំផ្សាយពាណិជ្ជកម្មអាចស្នើសុំបន្តសុពលភាពលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ មុនពេលផុតសុពលភាព។ ការស្នើសុំបន្តសុពលភាពនេះ អាចផ្តល់ជូនតែមួយលើកនិងមិនលើសពីជម្រើសនៃការស្នើសុំលើកទី១(មួយ) ចំពោះការផ្សាយពាណិជ្ជកម្មដោយមិនផ្តល់រង្វាន់តែប៉ុណ្ណោះ។

ក្នុងករណីដែលមានការផ្លាស់ប្តូរអត្ថបទឬស្លាតផ្សាយពាណិជ្ជកម្ម បុគ្គលស្នើសុំផ្សាយ ត្រូវស្នើសុំលិខិតបញ្ជាក់អនុលោមភាពនៃការផ្សាយពាណិជ្ជកម្មជាថ្មី។

**ប្រការ៨ ._**

នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ«ក.ប.ប.» អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៨រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន**........................

លេខ:.............................

## ពាក្យស្នើសុំផ្តល់អនុលោមភាព
## លើអត្ថបទឬស្គ្រីបផ្សាយពាណិជ្ជកម្ម

ខ្ញុំបាទ/នាងខ្ញុំ..........................................អាយុ........ឆ្នាំ អាសយដ្ឋានផ្ទះលេខ...........ផ្លូវ.............
ភូមិ.................................សង្កាត់.......................................ខណ្ឌ...........................................
រាជធានី/ខេត្ត..............................ទូរសព្ទលេខ .............................ជា..................ក្រុមហ៊ុន................
.....................................................អាសយដ្ឋានក្រុមហ៊ុនលេខ..............ផ្លូវ.........................................
ភូមិ.................................សង្កាត់.......................................ខណ្ឌ...........................................
រាជធានី............................................Telegram.................................................................។

### សូមគោរពជូន
### ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក
### នៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែងនិងបង្ក្រាបការក្លែងបន្លំ

**កម្មវត្ថុ៖** សំណើសុំផ្តល់លិខិតបញ្ជាក់អនុលោមភាពលើអត្ថបទឬស្គ្រីបផ្សាយពាណិជ្ជកម្ម។

តបតាមកម្មវត្ថុខាងលើខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមប្រតិភូ** មេត្តាជ្រាបថា៖ ក្រុមហ៊ុនរបស់ខ្ញុំបាទ/នាងខ្ញុំមានតម្រូវការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញនិង/ឬសេវា.........................................
...................................................................................................................................
ផលិតផលក្នុងស្រុក/នាំចូលពីប្រទេស.....................................................................................
អត្ថបទឬស្គ្រីបផ្សាយពាណិជ្ជកម្ម (Scrip)........................................................................
...................................................................................................................................
...................................................................................................................................
...................................................................................................................................
តាមទម្រង់និងមធ្យោបាយ រួមទាំងមធ្យោបាយឌីជីថល....................................................................
...................................................................................................................................
ប្រភេទនៃការផ្សាយពាណិជ្ជកម្មដោយ......................................................................................
ផលិតផលទំនិញសរុបដែលមានរង្វាន់......................................................................................
ប្រភេទរង្វាន់ និងចំនួនរង្វាន់សរុប.........................................................................................
លក្ខខណ្ឌនៃការផ្តល់រង្វាន់.....................................................................................................
ទីតាំងដាក់លាក់ដែលត្រូវផ្តល់រង្វាន់.........................................................................................
មានសុពលភាពរយៈពេល..............................ពីថ្ងៃទី.....ខែ.....ឆ្នាំ២០......ដល់ថ្ងៃទី........ខែ......ឆ្នាំ២០.....។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាគោរពបំពេញកាតព្វកិច្ចតាមលក្ខខណ្ឌតម្រូវអំពីការផ្តល់អត្តសញ្ញាណអ្នកឈ្នះនិងអ្នកត្រូវរង្វាន់ ជាប្រចាំខែ ប្រចាំឆ្នាំ និងទទួលខុសត្រូវចំពោះមុខច្បាប់ពាក់ព័ន្ធជាធរមាន។

សូមជូនភ្ជាប់ជាមួយនូវ៖

| | | |
|---|---|---|
| ១. | CD ឬVCD ឬDVD ឬUSB...........ជាស្គតគំរូ ( បើមាន ) | ១ឯកតា |
| ២. | ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | ១ច្បាប់ |
| ៣. | ច្បាប់ចម្លងលិខិតអនុញ្ញាតប្រកបអាជីវកម្មតាមវិស័យ | ១ច្បាប់ |
| ៤. | ច្បាប់ចម្លងលិខិតបញ្ជាក់ភាពត្រឹមត្រូវនៃផលិតផលទំនិញនិង/ឬសេវា | ១ច្បាប់ |
| ៥. | ច្បាប់ចម្លងប័ណ្ណប៉ាតង់ឆ្នាំចុងក្រោយ/ពន្ធអាករលើតម្លៃបន្ថែម( VAT )ចំពោះអាជីវកម្មដែលជាប់ពន្ធតាមរបបស្វ័យប្រកាស | ១ច្បាប់ |
| ៦. | ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែនឬលិខិតដែលមានតម្លៃស្មើ | ១ច្បាប់ |
| ៧. | ប្រសិនបុគ្គលស្នើសុំជាបុគ្គលទទួលបានសិទ្ធិឱ្យចាត់ចែងផ្សាយពាណិជ្ជកម្មត្រូវមានលិខិតផ្ទេរសិទ្ធិពីក្រុមហ៊ុនជាកម្មសិទ្ធិករឬសេវាករ | ១ច្បាប់ |
| ៨. | ច្បាប់ចម្លងជាអាទិ៍ ទិដ្ឋាការ បញ្ជិកា ប្រតិវេទន៍ ដែលតម្រូវដោយក្រសួង ស្ថាប័នឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ | ១ច្បាប់ |
| ៩. | បង្កាន់ដៃបង់ប្រាក់កម្រៃសេវា | ១ច្បាប់ |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រតិភូ** មេត្តាពិនិត្យនិងសម្រេចផ្តល់អនុលោមភាពលើអត្ថបទឬស្គតផ្សាយពាណិជ្ជកម្មរបស់ខ្ញុំបាទ/នាងខ្ញុំដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រតិភូ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ......................ខែ.................ឆ្នាំ.........ព.ស.២៥៦....

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី........ខែ..........ឆ្នាំ២០...........

**ប្រធានក្រុមហ៊ុន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមហ៊ុន**.......................
លេខ:..............................

## តារាងបំពេញលក្ខខណ្ឌតម្រូវ

ខ្ញុំបាទ/នាងខ្ញុំ..........................................អាយុ........ឆ្នាំ អាសយដ្ឋានលេខ..........ផ្លូវ..................
ភូមិ.................................សង្កាត់.........................................ខណ្ឌ.................................................
រាជធានី/ខេត្ត..............................ទូរសព្ទលេខ .............................ជា..................ក្រុមហ៊ុន................
..................................................អាសយដ្ឋានក្រុមហ៊ុនលេខ..............ផ្លូវ..........................................
ភូមិ.................................សង្កាត់.........................................ខណ្ឌ.................................................
រាជធានី..........................................................Telegram...................................................។

តារាងនៃការផ្តល់រង្វាន់ប្រចាំខែ....................ឆ្នាំ.................
ប្រភេទរង្វាន់...........................................................

| ល.រ | ឈ្មោះ | ភេទ | អាសយដ្ឋាន | លេខ អត្តសញ្ញាណប័ណ្ណ | លេខទូរសព្ទ | ថ្ងៃខែឆ្នាំ ផ្តល់រង្វាន់ | ទីតាំង ផ្តល់រង្វាន់ |
|---|---|---|---|---|---|---|---|
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

ថ្ងៃ....................ខែ..............ឆ្នាំ............ព.ស.២៥៦...
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី................ខែ............ឆ្នាំ២០.........

**ប្រធានក្រុមហ៊ុន**